# បច្ចេកទេសចិញ្ចឹមជ្រូកជាលក្ខណៈគ្រួសារ

ដោយៈនាយកដ្ឋានផលិតកម្ម និងបសុព្យាបាល

## ១. អំពីពូជ

ពូជជ្រូកមានបីប្រភេទ គឺពូជក្នុងស្រុក ពូជនាំចូល និងពូជកូនកាត់ ។

### ១.១. ពូជក្នុងស្រុក

ជាពូជជ្រូកដែលងាយចិញ្ចឹម ធន់នឹងជំងឺ និងអាកាសធាតុ មិនរើសចំណី តែការលូតលាស់របស់វាយឺត និងមានមាឌតូច ។



- ពូជជ្រូកហៃណាំ : មានដើមកំណើតនៅប្រទេសចិន ។ រូបរាងរបស់វាគឺត្រចៀកក្រាស់ មាឌតូច សម្បុរស ឬសខ្មៅ។ មានទម្ងន់ ១០០គក្រ នៅពេលដែលវាមានអាយុពី ១០-១៥ខែ ។
- ពូជជ្រូកកំពត : មានប្រភពនៅខេត្តកំពត ។ វាមានច្រមុះវែង ខ្នងអ៊ែន ពោះធំ រោមខ្លី សម្បុរខ្មៅ ។ អាយុ ៨ខែ វាមានទម្ងន់ ៦០គក្រ។
- ពូជជ្រូកដំរី : មានដើមកំណើតនៅក្នុងប្រទេសយើង ខ្នងនិងក្បាលរបស់វាធំ មុខខុប ច្រមុះត្រង់ខ្លី ខ្លួនធំហើយក្រាស់ ពោះធំ ជើងមាំ ចិញ្ចឹម ១ឆ្នាំ មានទម្ងន់ ៨០គក្រ ។
- ពូជជ្រូកកណ្ដុរ : មានប្រភពមកពីប្រទេសឥណ្ឌា ក្បាលវាដូចកណ្ដុរ ច្រមុះស្រួច ត្រចៀកស្រួច ខ្លួនខ្លី ខ្នងអ៊ែន ពោះធំ ចិញ្ចឹម ១ឆ្នាំ មានទម្ងន់ ៦០គក្រ។

### ១.២. ពូជនាំចូល

ជាពូជជ្រូកដែលចិញ្ចឹមឆាប់បានទទួលផល មានការលូតលាស់លឿន រើសចំណី មិនសូវសម្របខ្លួនទៅ នឹងលក្ខខណ្ឌធម្មជាតិ ។ ក្នុងសៀវភៅនេះសូមលើកយកពូជជ្រូកនាំចូលមួយចំនួនដែលផ្ដល់នូវទិន្នផលសាច់ និងកូនខ្ពស់ មកជម្រាបជូនដូចជា ៖

- **ពូជជ្រូកយ៉កសៀរ** : មានប្រភពដើមពីប្រទេសអង់គ្លេស ។ វាមានសម្បុរស លូតលាស់លឿន និងមានកូនច្រើន
- ពូជជ្រូកឡិនដ្រាស់: មានប្រភពដើមមកពីប្រទេសដាណឺម៉ាក ដែលមានដងខ្លួនវែងជាងប្រភេទពូជជ្រូកផ្សេងទៀតមានសម្បុរស និងផលិតកូនបានច្រើន ។



ពូជជ្រូកយ៉កសៀរ



ពូជជ្រូកឡិនដ្រាស់

- **ពូជជ្រូកឌុយរ៉ុក** : មានប្រភពដើមមកពីប្រទេសអាមេរិក ។ មានសម្បុរត្នោត និងផលិតសាច់បានល្អ ។

១.៣ ពូជកូនកាត់

ជាពូជជ្រូកដែលបានមកពីការបង្កាត់រវាងបាពូជនាំចូលជាមួយមេពូជក្នុងស្រុក។ ពូជជ្រូកកូនកាត់មានការលូតលាស់លឿន មិនរើសចំណី និងធន់ទៅនឹងអាកាសធាតុ ។



ពូជជ្រូកឌុយរ៉ុក



ពូជកូនកាត់

## ២. ការជ្រើសរើសពូជ

ក. ជ្រូកបា

មានសារសំខាន់ណាស់ដល់ផលិតកម្មជ្រូក ព្រោះជ្រូកបា ១ ក្បាល អាចយកទៅបង្កាត់ជាមួយមេជ្រូកជាច្រើនក្បាលទៀត ។ ដូច្នេះដើម្បីឲ្យបានបាល្អត្រូវ ៖

- ធ្វើការជ្រើសរើសកូនជ្រូកដែលមេ-បា មានសុខភាពល្អ និងមានប្រភពច្បាស់លាស់
- កូនដែលកើតចេញពីមេជ្រូក ជាកូនក្នុងសំបុកដែលមានកម្លាំងមាំមួន
- មេរបស់វា ជាមេដែលមានកូនច្រើន និងមានដោះមិនតិចជាង ១២ ឬ(៦គូ)
- មានសុខភាពល្អ ជើងត្រង់ល្អ រឹងមាំ ក្រចកស្មើ ធំធាត់លឿន
- ប្រដាប់បន្តពូជល្អ (ពងស្វាសទាំងគូស្មើគ្នា)
- ស្បែករលោង ស្មាទូលាយ ខ្នងត្រង់ ទ្រូងបើក
- រហ័សរហួន មិនរើសចំណី
- មិនដែលមានកើតជំងឺឆ្លងណាមួយ
- មានអាយុចាប់ពី ៤៥ថ្ងៃឡើង និងមានទម្ងន់ ចាប់ពី ៥-៧គក្រ





ខ. ជ្រូកមេសម្រាប់ទុកពូជ

ដើម្បីឲ្យផលិតកម្មកូនបានច្រើន ហើយកូនធំធាត់លូតលាស់លឿន ចាំបាច់ត្រូវជ្រើសរើសមេដែល ៖

- មិនជាន់ឈាម (ខ្សែស្រឡាយជាមួយគ្នា)

- កើតចេញពីមេដែលមានកូនច្រើន ( យ៉ាងតិច ៩ក្បាល)
- មានឧមាំ ធំជាងគេក្នុងហ្វូង មានដោះមិនតិចជាង ៦គូ
- មានសុខភាពល្អ ជើងត្រង់ល្អ រឹងមាំ ក្រចកស្មើ ធំធាត់លឿន
- ប្រដាប់បន្តពូជលូតលាស់ល្អស្បែករលោង ស្មាទូលាយ ខ្នងត្រង់ ទ្រូងបើក រហ័សរហួន មិនរើសចំណី
- មិនដែលមានកើតជំងឺឆ្លងណាមួយ
- មានអាយុចាប់ពី ៤៥ថ្ងៃឡើង និងមានទម្ងន់ចាប់ពី ៥-៧គក្រ




### គ. ជ្រូកសាច់

កូនដែលត្រូវជ្រើសរើសយកមកចិញ្ចឹមធ្វើជាជ្រូកសាច់ ដូចជា ៖

- កូនជ្រូកដែលបង្កាត់ពីរពូជបញ្ចូលគ្នា (មេពូជផ្សេង បាពូជផ្សេងពីគ្នា)
- ប្រវត្តិច្បាស់លាស់
- មេរបស់វា ជាមេដែលមានកូនច្រើន និងមានដោះមិនតិចជាង ១២ ឬ ៦ គូរ
- មានសុខភាពល្អ ជើងត្រង់ល្អ រឹងមាំ ក្រចកស្មើ ធំធាត់លឿន
- ប្រដាប់បន្តពូជល្អ
- ស្បែករលោង ស្មាទូលាយ ខ្នងត្រង់ ទ្រូងបើក
- រហ័សរហួន មិនរើសចំណី
- មិនដែលមានកើតជំងឺឆ្លងណាមួយ
- មានអាយុចាប់ពី ៤៥ថ្ងៃឡើង និងមានទម្ងន់ចាប់ពី ៥-៧គក្រ




ពូជជ្រូកយកសាច់

# ៣. ការសាងសង់ទ្រុង

### ក. ទីតាំង និងទំហំ

ទ្រុងត្រូវសាងសង់នៅលើដីដែលមិនលិចទឹក មិននៅជាប់នឹងផ្ទះ មានខ្យល់ ពន្លឺចេញចូលគ្រប់គ្រាន់ មានទីធ្លាសមស្រប និងមានទំហំទៅតាមប្រភេទជ្រូក ។

គួរសង់ទ្រុងបណ្ដោយថ្ងៃ និងគ្រប់គ្រងសីតុណ្ហភាពឲ្យបានត្រឹមត្រូវ ព្រោះសីតុណ្ហភាពជះឥទ្ធិពលខ្លាំង ដល់ការលូតលាស់របស់ជ្រូក (ទ្រុងជ្រូកសាច់ត្រូវមានសីតុណ្ហភាពពី ២៥-២៨អង្សាសេ ទ្រុងមេបំបៅកូន និងផ្ដាច់ដោះ ត្រូវមានសីតុណ្ហភាពពី ៣៧-៣៨អង្សាសេ) ។

ដើម្បីធានាដល់សុវត្ថិភាពកូនជ្រូក និងដើម្បីឲ្យមេជ្រូកងាយស្រួលបំបៅកូន ព្រមទាំងកុំឲ្យមេដេកសង្កត់ ត្រូវយកចិត្តទុកដាក់បំផុតចំពោះទ្រុងមេកើតកូន ។

តារាងបង្ហាញពីទំហំទ្រុងទៅតាមប្រភេទជ្រូក នីមួយៗ

| ប្រភេទជ្រូក | ទំហំ (បណ្ដោយ × ទទឹង) | កម្ពស់ទ្វារ |
|---|---|---|
| ជ្រូកក្រមុំ | ១.០០ម × ២.០០ម | ១.០០ម |
| មេបំរុង ឬមេជើម | ០.៦០-០.៦៥ម × ២.២០ម | ១.០០ម |
| ជ្រូកបាមានកន្លែងសម្រាប់បង្កាត់ | ២.២០-២.៣០ម × ៤.០០ម | ១.០០-១.៥០ម |
| មេបំបៅកូន | ៣.០០ម² | ១.០០ម |
| កូនផ្ដាច់ដោះ | ២.៥០ម × ៣.០០ម (សម្រាប់កូន ១២ក្បាល) | ០.៦០ម |
| ជ្រូកសាច់ទម្ងន់ពី ៣០-៦០គក្រ | ០.៧០ម × ១.០០ម | ១.០០ម |
| ជ្រូកសាច់ទម្ងន់ ៦១គក្រ ដល់លក់ | ១.២០ម × ១.០០ម | ១.០០ម |

ទ្រុងត្រូវតែមានទ្វារមុខ និងទ្វារក្រោយ ដើម្បីងាយស្រួលចល័តពីកន្លែងមួយទៅកន្លែងមួយទៀត ។

ទ្រុងសម្រាប់មេបំបៅ ត្រូវរៀបចំជាបីផ្នែក ៖

- ទ្រុងសម្រាប់មេទំហំ ០.៦៥ម × ២.២០ម
- ទីតាំងសម្រាប់កូនដេកទំហំ ០.០២ម × ២.២០ម
- ទីតាំងសម្រាប់កូនស៊ីចំណី និងផឹកទឹកទំហំ ០.៦៥ម × ២.២០ម

### ខ. កម្រាល និងទីធ្លា

ជាទូទៅច្រើនធ្វើពីស៊ីម៉ងត៍ ដែលមានផ្ទៃរាបស្មើ និងកម្រាលរឹងមាំ។ កម្រាលគួរតែធ្វើទេរទៅផ្នែកខាងក្រោយបន្តិចដោយមានកន្លែងសម្រាប់បង្ហូរលាមក និងទឹក។



